# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ: 102 ប្រក.កសក

# ប្រកាស

## ស្តីពី

## ការបង្កើតចំការពូជឈើក្នុងព្រៃសម្បទានសហគ្រាសកូឡិចស៊ីម ក្នុងប្លុកលេខ ៨ គុបលេខ IV-12 អនុតំបន់ IV នៅឃុំទីវែង ស្រុកសណ្ដាន់ ខេត្តកំពង់ធំ

~~~~~~~~~~

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញក្រឹត្យ-ច្បាប់លេខ ៣៥ក្រ.ច ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ១៩៨៨ ស្តីពីការគ្រប់គ្រងវិស័យព្រៃឈើ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- តាមសំណើរបស់ប្រធាននាយកដ្ឋាន រុក្ខា-ប្រមាញ់

## សំរេច

**ប្រការ១ :** បង្កើតចំការពូជឈើមួយកន្លែង មានផ្ទៃដីទំហំ **១១៧ ហិកតា** ដែលមានទីតាំងស្ថិតនៅ ប្លុកលេខ ៨ គុបលេខ IV-12 អនុតំបន់ IV ក្នុងព្រៃសម្បទានសហគ្រាសកូឡិចស៊ីម ក្នុងឃុំទីវែង ស្រុកសណ្ដាន់ ខេត្តកំពង់ធំ ដើម្បីធ្វើការអភិរក្សធនធានសេនេទិច និង ធ្វើការប្រមូលគ្រាប់ពូជសំរាប់ផ្គត់ផ្គង់ដល់ការដាំឈើ និង ដាំឈើឡើងវិញរួមមាន ចំនួន ៦ ប្រភេទ គឺ : **ផ្ចឹតថែម ករកោះ ឈើទាល ផ្ចៀក លំពោរ និង ធ្នង់ចុង ។**

**ប្រការ២ :** ការរៀបចំ និង ការប្រព្រឹត្តិទៅរបស់ចំការពូជឈើនេះ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់នាយកដ្ឋាន រុក្ខា-ប្រមាញ់ ( ការិយាល័យដាំឈើ) សហការជាមួយសហគ្រាសកូឡិចស៊ីម និង មានការបែងចែកទទួលភារកិច្ច ដូចតទៅ :

-នាយកដ្ឋានរុក្ខា-ប្រមាញ់ ( ការិយាល័យដាំឈើ ) មានភារកិច្ចត្រួតពិនិត្យ តាមដានលើផ្នែកបច្ចេកទេស សេនេទិច និងរុក្ខវប្បកម្មនៃប្រភេទពូជឈើនីមួយៗ និង ធ្វើការប្រមូលគ្រាប់ពូជជារៀងរាល់ឆ្នាំ សំរាប់ បំរើឱ្យការងារដាំឈើ និងដាំឈើឡើងវិញ ។

Downloaded from http://www.khmerlaws.com
~~~~~~~~~~

-២-

-សហគ្រាសកូឡិចស៊ីម មានតួនាទីភារកិច្ចគ្រប់គ្រងថែរក្សា ការពារ បង្ការភ្លើងព្រៃ និង ចាត់វិធានការនូវគ្រប់រូបភាពអនាធិបតេយ្យក្នុងចំការព្នជរឈើនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់បំផុត។

**ប្រការ៣ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៤ :** អគ្គនាយកនៃក្រសួង អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល ប្រធាននាយកដ្ឋានបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស ប្រធាននាយកដ្ឋានផែនការ-ស្ថិតិនិងសហប្រតិបត្តិការអន្តរជាតិ ប្រធាននាយកដ្ឋានរុក្ខា-ប្រមាញ់ ប្រធានសហគ្រាសកូឡិចស៊ីម និង ប្រធានមន្ទីរកសិកម្មរុក្ខា-ប្រមាញ់ និងនេសាទខេត្តកំពង់ធំ ត្រូវទទួលបន្ទុករៀង១ខ្លួនអនុវត្តប្រកាសនេះឱ្យទទួលបានប្រសិទ្ធិភាពខ្ពស់ ។

**ប្រការ៥ :** ប្រកាសនេះ មានអានុភាពគតិយុត្តិចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ ៣ ឆ្នាំ ២០០២

**រដ្ឋមន្ត្រី**

ចាន់ សារុន

**កន្លែងទទួល:**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-ក្រសួងបរិស្ថាន

-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

-សាលាខេត្តកំពង់ធំ

"ដើម្បីជូនជ្រាប"

-ដូចមានចែងក្នុងប្រការ៤

"ដើម្បីអនុវត្ត"

-ឯកសារ - កាលប្បវត្តិ

Downloaded from http://www.khmerlaws.com